00364047

D158/5/1/15


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២១)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី:** សរ ចំនួរ៉ាត
Entela JOSIFI

**កាលបរិច្ឆេទ:** ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 08 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Aug

---

## សាធារណៈ:

## សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 18 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Aug

**ជនត្រូវចោទ**
នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**សហមេធាវីការពារក្តី**
សុន អរុណ
Michiel PESTMAN
Victor KOPPE
MAM Thanna
Andrew IANUZZI

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00364048

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២១)

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទីដប់មួយ សុំបើកកិច្ចស៊ើបសួរ" ដែលបានដាក់ដោយសហមេធាវីការពារក្តីរបស់លោក នួន ជា ("ជនត្រូវចោទ") នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍")។

## I. សាវតានីតិវិធី

១. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់ "សំណើលើកទីដប់មួយ សុំបើកកិច្ចស៊ើបសួរ" ("សំណើលើកទីដប់មួយ") ចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើការចោទប្រកាន់អំពីអំពើពុករលួយនៅ អ.វ.ត.ក[១]។

២. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ[របស់ជនត្រូវចោទ]" ("ដីកាសម្រេច")។ នៅក្នុងដីកាសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ខ្លួនពុំមានយុត្តាធិការចាំបាច់បំពេញកិច្ចស៊ើបសួរដែលបានស្នើសុំនោះឡើយ ហើយថា សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើករណីរដ្ឋបាល គឺជា"រឿងមិនចាំបាច់"[២]។

៣. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ដីកាសម្រេចនេះត្រូវបានជូនដំណឹងដល់ជនត្រូវចោទ។

៤. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹឧទ្ធរណ៍ ហើយនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ (បណ្តឹងឧទ្ធរណ៍)[៣]។ នៅថ្ងៃទី៧ ខែឧសភា

---

[១] សំណើលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួរ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D158 កថាខណ្ឌ១៧ ("សំណើលើកទី១១")។

[២] ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ D158/5 កថាខណ្ឌ១០-១៣ ("ដីកាសម្រេច") ។

[៣] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, D158/5/1/1 ("បណ្តឹងឧទ្ធរណ៍")។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ឆ្នាំ២00៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់“ឯកសារបន្ថែម”ទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន[៤]។

៥. នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២00៩ សហព្រះរាជអាជ្ញាបានដាក់ពាក្យសុំស្តីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍[៥]។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២00៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់ភាគីនានា ឲ្យលើកឡើងមតិយោបល់របស់ខ្លួនចំពោះពាក្យសុំរបស់សហព្រះរាជអាជ្ញា[៦]។

៦. នៅថ្ងៃទី២0 ខែឧសភា ឆ្នាំ២00៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ (“សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)[៧]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២00៩ ដោយបានឃើញសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលកំណត់ដើម្បីដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[៨] អង្គបុរេជំនុំជម្រះបានទទួលយកសារណាតបរបស់

---

[៤] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ “ឯកសារបន្ថែម” ថ្ងៃទី៧ ខែឧសភា ឆ្នាំ២00៩, D158/5/1/2។

[៥] ពាក្យសុំរបស់សហព្រះរាជអាជ្ញាស្តីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីអំពើពុករលួយ, ថ្ងៃទី៦ ខែឧសភា ឆ្នាំ២00៩, D158/5/1/3។

[៦] សេចក្តីបង្គាប់ដល់ភាគី ទាក់ទងនឹងពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យបន្ថែមទំព័រ និងពេលវេលាកំណត់ ដើម្បីការដាក់ឯកសារសេចក្តីឆ្លើយតបរួមគ្នារបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាសម្រេចស្តីពីអំពើពុករលួយ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២00៩, D158/5/1/4។

[៧] សារណាតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្តីអំពីបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា, អៀង សារី, ខៀវ សំផន និងអៀង ធីរិទ្ធ ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីសំណើលើកទី១១ ស្នើសុំឲ្យមានកិច្ចស៊ើបសួរ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២00៩, D158/5/1/10 (“សារណាតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី”)។

[៨] សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលកំណត់ក្នុងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីប្រឆាំងនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ស្តីពីអំពើពុករលួយ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២00៩, D158/5/1/5។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់យឺតពេលកំណត់ អនុលោមតាមវិធាន៣៩(៤) នៃវិធានផ្ទៃក្នុង និងមាត្រា៩ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[៩]។

៧. នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានបដិសេធពាក្យសុំរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យបន្ថែមទំព័រ ប៉ុន្តែទទួលយកសំណើសុំពន្យារពេលវេលាកំណត់ដើម្បីដាក់ចម្លើយតប ដោយពន្យារពេលវេលាកំណត់រហូតដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩[១០]។

៨. សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩[១១]។

៩. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីជនត្រូវចោទ ដោយបង្គាប់ឱ្យសហមេធាវីការពារក្តីដាក់សារណាតបទៅនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍[១២]។

---

[៩] សេចក្តីសម្រេចស្តីពីការទទួលយកការដាក់សារណាតបយឺត របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩, D158/5/1/7។

[១០] សេចក្តីសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យបន្ថែមទំព័រ និងពេលវេលាកំណត់ដើម្បីដាក់ឯកសារសេចក្តីឆ្លើយតបរួមគ្នារបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាសម្រេចស្តីពីអំពើពុករលួយ, ថ្ងៃ២២ ខែឧសភា ឆ្នាំ២០០៩, D158/5/1/9។

[១១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើសុំឱ្យមានកិច្ចស៊ើបសួរទាក់ទិននឹងការចោទប្រកាន់អំពីអំពើពុករលួយ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩, D158/5/1/11 ("ចម្លើយតបរួម")។

[១២] សេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីជនត្រូវចោទពាក់ព័ន្ធនឹង "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើសុំឱ្យមានកិច្ចស៊ើបសួរទាក់ទិននឹងការចោទប្រកាន់អំពើពុករលួយ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩, D158/5/1/12 ("សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ")។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១០. សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ការឆ្លើយតបរបស់ខ្លួន តាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩[១៣]។

១១. នៅពេលទទួលបានការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿង ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ។ ដើម្បីធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានពិនិត្យមើលឯកសារនានានៅក្នុងសំណុំរឿង និងភស្តុតាងទាំងអស់ ដែលបានដាក់បន្ថែមរហូតមកទល់ពេលដែលសហមេធាវីការពារក្តីជនត្រូវចោទបានដាក់ការឆ្លើយតប តាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ដែលជាថ្ងៃចុងក្រោយអនុញ្ញាតិឱ្យភាគីនានាផ្តល់មតិយោបល់ផ្សេងៗ ឬដាក់ភស្តុតាង ដើម្បីបានជាប្រយោជន៍សម្រាប់ខ្លួន។

## II. ច្បាប់ពាក់ព័ន្ធ

១២. សេចក្តីសំអាងបានយោងលើមាត្រា២១(១), មាត្រា ៣៥, មាត្រា៥៥(១០), មាត្រា៥៨(៦), មាត្រា ៧៣, និងមាត្រា៧៤(៣)(ខ)។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៣. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើលើកទីដប់មួយ។ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ដីកាសម្រេចបានជូនដំណឹងដល់ជនត្រូវចោទ។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ សារណាបណ្តឹងឧទ្ធរណ៍ បានដាក់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះបានដាក់នៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធាន៧៥(៣) នៃវិធានផ្ទៃក្នុង។

---

[១៣] ការឆ្លើយតបរបស់សហមេធាវីការពារក្តីទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩, D158/1/13 ("ការឆ្លើយតបរបស់សហមេធាវីការពារក្តី")។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយ របស់ជនត្រូវចោទ សុំបើកកិច្ចស៊ើបសួរ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

១៤. សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន៧៣ វិធាន៧៤ និង វិធាន៧៥ នៃវិធានផ្ទៃក្នុង[14] ដោយ បានលើកឡើងដូចខាងក្រោមនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍៖

"វិធាន៧៣នៃវិធានផ្ទៃក្នុងផ្តល់ឲ្យ[អង្គបុរេជំនុំជម្រះ]នូវយុត្តាធិការ លើតែបណ្តឹងឧទ្ធរណ៍ប្រឆាំង នឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ដូចមានចែងនៅក្នុងវិធាន៧៤នៃ វិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ៧៣(៣)(ខ) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណា មួយរបស់សហចៅក្រមស៊ើបអង្កេតដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដូចមានចែង នៅក្នុងវិធានផ្ទៃក្នុង"[15]។

១៥. សហមេធាវីការពារក្តីជនត្រូវចោទបានតវ៉ាថា អ.វ.ត.ក មានអំណាចជាប់មកជាមួយ (inherent power) ដោះស្រាយលើទង្វើជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[16]។ សហមេធាវីការ ពារក្តីបានតវ៉ាថា "តុលាការត្រូវធ្វើយ៉ាងណាឱ្យខ្លួនឯងជឿថា ដំណើរការនីតិវិធីទាំងមូល មានភាព យុត្តិធម៌ ដោយត្រូវធ្វើការពិចារណាលើអនីយ័តភាពនានាដែលអាចកើតមានឡើងមុនពេលរឿងក្តីនេះ បានដាក់នៅចំពោះមុខខ្លួន ក្នុងនោះរួមទាំងរបៀបនៃចំណាត់ការចំពោះភស្តុតាងផងដែរ"[17]។

១៦. សហមេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា វិធាន៣៥នៃវិធានផ្ទៃក្នុងផ្តល់អំណាចឲ្យ អ.វ.ត.ក ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនា ពិតប្រាកដដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[18]។

១៧. យោងតាមទម្រង់នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាមិនបានដេញដោលលើភាពអាចទទួលយក បាននៃបណ្តឹងឧទ្ធរណ៍នោះទេ នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍[19]។

---

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៧។

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០-១២។

[17] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៣។

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

១៨. សហព្រះរាជអាជ្ញាបានសន្និដ្ឋាននៅក្នុងចម្លើយតបរបស់ខ្លួនថា អនុលោមតាមវិធានផ្ទៃក្នុង សំណើលើកទឹងប់មួយមិនស្ថិតនៅក្រោមយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតឡើយ[២០] ហើយការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះក៏មិនបានបង្ហាញឱ្យឃើញផងដែរ[២១]។ សហព្រះរាជអាជ្ញាក៏បានតវ៉ាផងដែរថា សំណើលើកទឹងប់មួយក៏មិនស្ថិតនៅក្រោមយុត្តាធិការដែលមានជាប់មកជាមួយ (inherent jurisdiction) របស់តុលាការនេះដែរ[២២]។

១៩. នៅក្នុងចម្លើយតបរបស់ខ្លួនតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២00៩ សហមេធាវីការពារក្តីជនត្រូវចោទមិនបានផ្តល់មតិយោបល់លើចម្លើយតបរបស់សហព្រះរាជអាជ្ញាឡើយ។

២០. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្លួនគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើលើកទឹងប់មួយរបស់សហមេធាវីការពារក្តីជនត្រូវចោទ "សុំឱ្យ អ.វ.ត.ក ស៊ើបអង្កេតបន្ថែមទៀតលើអំពើពុករលួយ" ហើយ "អ.វ.ត.ក ជាពិសេសសហចៅក្រមស៊ើបអង្កេត មានសមត្ថកិច្ចបើកកិច្ចស៊ើបសួរលើបញ្ហានេះ[២៣]"។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថា "ដោយសារតែ អ.វ.ត.ក ដំណើរការទៅដោយផ្អែកទៅលើភាពមិនលំអៀង និងឯករាជ្យភាពនៃតុលាការ [...] ការដោះស្រាយលើបញ្ហានេះស្ថិតនៅក្នុងវិសាលភាពរបស់ អ.វ.ត.ក មិនថាបញ្ហានេះមានភាពអាម៉ាស់យ៉ាងណាក៏ដោយ"[២៤]។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមទៀតថា "វាមានមន្ទិលសង្ស័យតិចប៉ុណ្ណោះដែលថាការស៊ើបអង្កេតលើកករណីនេះស្ថិតនៅក្នុងវិសាលភាពនៃវិធាន៣៥ នៃវិធានផ្ទៃក្នុង ឬយ៉ាងណា"[២៥] ហើយអំណាច

---

[១៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៤។

[២០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥៤-៥៧។

[២១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦0 និង៦១។

[២២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦២-៦៤។

[២៣] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៤។

[២៤] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៥-១0។

[២៥] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១១។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00364054



ជាប់មកជាមួយនេះទាមទារឲ្យសាលាក្តីទាំងឡាយ ដោះស្រាយទង្វើជ្រៀតជ្រែកដល់កិច្ចការរដ្ឋបាល[របស់ខ្លួន]"[២៦]។ យោងតាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំណាចជាប់មកជាមួយនេះ "រួមជាមួយនឹងអំណាចដូចមានចែងនៅក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង បង្កើតបានជាយុត្តាធិការសម្រាប់ អ.វ.ត.ក ក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ និងក្នុងការបើកកិច្ចស៊ើបសួរបន្ថែមលើករណីនេះ"[២៧]។

## ការពិចារណារបស់អង្គបុរេជំនុំជម្រះ

២១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អនុលោមតាមវិធាន៧៣ នៃវិធានផ្ទៃក្នុង ខ្លួនមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងប្រឆាំងនឹងប្រភេទនៃសេចក្តីសម្រេចមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត "ដូចមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង"។ វិធាន៧៤(៣)(ខ) ផ្តល់ឲ្យជនត្រូវចោទនូវសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបដិសេធ"ពាក្យសុំបើកកិច្ចស៊ើបសួរទាំងឡាយ ដែលបានអនុញ្ញាតក្រោមវិធានផ្ទៃក្នុងនេះ"។ នៅពេលយើងយកឃ្លា "ដូចមានចែងនៅក្នុងវិធាន៧៤នៃវិធានផ្ទៃក្នុង" នៅក្នុងវិធាន៧៣(ក)នៃវិធានផ្ទៃក្នុង មកអានរួមជាមួយនឹងបទប្បញ្ញត្តិវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង វាបានបង្ហាញថា ដើម្បីអាចអនុវត្តវិធាន៧៣(ក) នៃវិធានផ្ទៃក្នុងបាន បុរេលក្ខខណ្ឌចំនួនពីរត្រូវតែបំពេញ។ បុរេលក្ខខណ្ឌទីមួយគឺ ត្រូវមានសំណើសុំ "ដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង" និងបុរេលក្ខខណ្ឌទីពីរគឺ សំណើសុំនោះត្រូវតែបាន "បដិសេធ" ដោយសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ នៅក្នុងករណីមួយនេះ បញ្ហាចម្បងនៃភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះគឺថា តើសំណើលើកទីដប់មួយស្នើសុំបើកកិច្ចស៊ើបសួរ "ត្រូវបានអនុញ្ញាតតាមវិធានផ្ទៃក្នុង" ដែរឬទេ។

---

[២៦] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៣។

[២៧] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៤។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២២. សំណើលើកទីដប់មួយស្នើសុំបើកកិច្ចស៊ើបសួរ គឺដើម្បីចង់បានព័ត៌មានដែលអាចបង្ហាញពី "អំពើពុករលួយនៅក្នុងស្ថាប័ន" របស់អ.វ.ត.ក។ សំណើលើកទីដប់មួយនេះ ផ្អែកលើមូលដ្ឋានច្បាប់មួយចំនួន ក្នុងនោះរួមមានវិធាន២១(១) វិធាន៥៥(១០) និងវិធាន៥៨(៦)នៃវិធានផ្ទៃក្នុង។

២៣. នៅក្នុងបណ្តឹងឧទ្ធរណ៍ និងសារណាតបរបស់ខ្លួន តាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទមិនបានផ្តល់ការពន្យល់គ្រប់គ្រាន់ថាតើសំណើសុំព័ត៌មានចំពោះការចោទប្រកាន់ អាចត្រូវគ្នាយ៉ាងដូចម្តេចទៅនឹងអត្ថន័យនៃវិធានច្បាប់ "ពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង" ដូចមានចែងនៅក្នុងវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។ សហមេធាវីការពារក្តីគ្រាន់តែអះអាងថា "វិធាន៧៣ នៃ [វិធានផ្ទៃក្នុង] ផ្តល់ឱ្យ[អង្គបុរេជំនុំជម្រះ]នូវយុត្តាធិការទាំងស្រុងលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន៧៤ [នៃវិធានផ្ទៃក្នុង]"។

២៤. យោងតាមវិធានផ្ទៃក្នុង សំណើសុំបើកកិច្ចស៊ើបសួរដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង រួមមានសំណើដែលដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុង។ សំណើលើកទីដប់មួយបានអះអាងថា បានផ្អែកលើសម្អាងផ្លូវច្បាប់ទាំងនេះ។ ដូច្នេះ នៅពេលពិនិត្យតាមរបៀបនេះ វាហាក់ដូចជាសំណើលើកទីដប់មួយស្ថិតក្នុងប្រភេទនៃសំណើសុំ "ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង"។ ប៉ុន្តែ ផ្ទុយពីការអះអាងទាំងនេះរបស់ជនត្រូវចោទ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុដែលជនត្រូវចោទស្នើសុំឱ្យដោះស្រាយតាមរយៈការដាក់សំណើលើកទីដប់មួយ មិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុងនោះទេ។ អង្គហេតុដែលជនត្រូវចោទបានចោទប្រកាន់ ហើយស្នើសុំឱ្យដោះស្រាយគឺអង្គហេតុមួយដែលអាចបង្ហាញអំពី "ការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ឬ "អំពើពុករលួយ" នៅក្នុង អ.វ.ត.ក។ វិធាន៥៥(១០) និងវិធាន៥៨(៦) ត្រូវយកមកអានឱ្យស្របគ្នាជាមួយនឹងអនុវិធាន១ នៃវិធាន ៥៥(១) នៃវិធានផ្ទៃក្នុង ដែលចែងដូចតទៅ៖



* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

00364056



"ការសើុបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា យុត្តាធិការរបស់ អ.វ.ត.ក កើតចេញពីកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[២៨] ដែលជាលិខិតុបករណ៍បង្កើតស្ថាប័ន អ.វ.ត.ក។ លិខិតុបករណ៍ទាំងនេះសំដៅទៅលើតែ "ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" តែប៉ុណ្ណោះ។ ពុំមានឧបប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀង ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងយោងអំពី "អំពើនានា" ដែលជា "ការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ឬ "អំពើពុករលួយ" ដូចដែលបានលើកឡើងនោះទេ។

២៦. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា "អំពើនានា" ដែលជា "ការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" មានចែងនៅក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង។ អនុលោមតាមបុព្វកថានៃវិធានផ្ទៃក្នុង គោលបំណងនៃវិធានផ្ទៃក្នុងមិនមែនដើម្បីកំណត់នូវអំណាចរបស់ អ.វ.ត.កទេ។ ប៉ុន្តែវិធានផ្ទៃក្នុងមានគោលបំណង៖

> "ប្រមូលនូវនីតិវិធីជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និង[...] អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ"។

២៧. វិធាន៣៥នៃវិធានផ្ទៃក្នុងចែងថា អ.វ.ត.ក "អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច" នូវជនណាម្នាក់ដែល "ជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"។ វិធាននេះ បង្ហាញអំពីកិច្ច

---

[២៨] សូមអានមាត្រា២(១) និងមាត្រា៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ "កិច្ចព្រមព្រៀង" ដូចដែលមានចែងស្របគ្នាជាមួយមាត្រា៣, ៤, ៥, ៦, ៧ និង៨ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ខិតខំប្រឹងប្រែងដើម្បីដោះស្រាយ "បញ្ហាពិសេស" ដូចមានចែងនៅក្នុងបុព្វកថានៃវិធានផ្ទៃក្នុង ដើម្បីការពារនីតិវិធីចំពោះមុខ អ.វ.ត.ក ពីសកម្មភាពមិនសមរម្យ ដែលអាចបង្កើតភាពអយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធី។ វិធាន ៣៥នៃវិធានផ្ទៃក្នុង ពុំបានបង្កើតយុត្តាធិការចំបងបន្ថែមសម្រាប់ អ.វ.ត.ក ឡើយ ដែលចំនុចនេះវាហួសពីវិសាលភាពនៃវិធានផ្ទៃក្នុង យ៉ាងច្បាស់។ អំណាចដែលផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដើម្បីដោះស្រាយនូវអំពើនានាដែលអាចជា "ការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" បង្ហាញយ៉ាងច្បាស់ថា វាជាទម្រង់នៃយុត្តាធិការបន្ទាប់បន្សំសម្រាប់ អ.វ.ត.ក តែប៉ុណ្ណោះ។ យុត្តាធិការនេះពុំពាក់ព័ន្ធទៅនឹងយុត្តាធិការ ដូចមានចែងនៅក្នុងវិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុងនោះទេ។

២៨. នៅក្នុងបរិបទនេះ សំណើលើកទីដប់មួយលើកឡើងលាយឡំគ្នាមិនត្រឹមត្រូវរវាងអង្គហេតុដែលបានចោទប្រកាន់ និងបទប្បញ្ញត្តិច្បាប់ ដែលសហមេធាវីការពារក្តីជនត្រូវចោទ បានយកមកផ្អែកដើម្បីបង្កើតជាយុត្តាធិការសម្រាប់សំណើរបស់ខ្លួន។ វិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុង មិនអាចយកមកប្រើប្រាស់ជាមូលដ្ឋានច្បាប់ សម្រាប់ដាក់សំណើសុំបើកកិច្ចស៊ើបអង្កេតចំពោះអង្គហេតុ ដែលអាចបង្ហាញពីការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬអំពើពុករលួយនៅក្នុងអ.វ.ត.ក ឡើយ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើលើកទីដប់មួយពុំស្ថិតនៅក្នុងប្រភេទនៃ"សំណើសុំឱ្យមានកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុងទេ" នោះទេ។

២៩. ចំពោះវិធាន៣៥នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីជនត្រូវចោទយោងដោយប្រយោលលើមាត្រានេះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដោយបានលើកឡើងថា វិធាននេះផ្តល់អំណាចឱ្យ អ.វ.ត.ក បើកកិច្ចស៊ើបអង្កេតលើ "ការជ្រៀតជ្រែតកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[២៩]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងនេះមិនមានចែងអំពីការផ្តួចផ្តើមបើកកិច្ចស៊ើបសួរតាមសំណើរបស់ភាគីណាមួយនោះទេ។ ប៉ុន្តែវិធានផ្ទៃក្នុងបានផ្តល់ឆន្ទានុសិទ្ធិដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។ ហេតុដូច្នេះ វិធាន៣៥នៃវិធានផ្ទៃក្នុងមិនអាចផ្តល់មូលដ្ឋានអនុញ្ញាត្តិឱ្យ

---

[២៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០។

ភាគីស្នើសុំបើកកិច្ចស៊ើបសួរ ហើយបើកឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ខ)នៃវិធានផ្ទៃក្នុងឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា ករណីនេះកំពុងស្ថិតនៅចំពោះមុខស្ថាប័នសមស្របគឺ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

**<u>សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង</u>**

៣០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីបានលើកឡើងនូវការព្រួយបារម្ភថា ការចោទប្រកាន់ថាមានអំពើពុករលួយពាសពេញស្ថាប័ន អាចគម្រាមកំហែងដល់សិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះដោយឯករាជ្យ និងមិនលម្អៀង។ សហមេធាវីការពារក្តីបានតវ៉ាថា ប្រសិនបើបុគ្គលិកដែលទទួលភារកិច្ចបំពេញការងារសើប មានឆន្ទៈចូលរួមពាក់ព័ន្ធនៅក្នុងអំពើពុករលួយនោះ នៅពេលនោះបុគ្គលទាំងនោះក៏អាចនឹងមានឆន្ទៈដូចគ្នា ក្នុងការអនុវត្តតាមសេចក្តីណែនាំដែលមិនសមរម្យ ដូចជាការរៀបចំឱ្យមានភស្តុតាងដើម្បីគាំទ្រលទ្ធផលនយោបាយដែលគ្រោងទុក។ សហមេធាវីការពារក្តីអះអាងថា គោលបំណងចំបងនៃសំណើលើកទីដប់មួយ គឺដើម្បីបញ្ជាក់ជូនដល់ជនត្រូវចោទ និងសាធារណជនថា ចៅក្រមព្រះរាជអាជ្ញា បុគ្គលិករដ្ឋបាល និងបុគ្គលិកគាំទ្ររបស់ អ.វ.ត.ក បំពេញតាមបទដ្ឋានសុចរិតភាព និងសេរីភាព ដោយពុំបានទទួលឥទ្ធិពលនយោបាយឡើយ[៣០]។

៣១. សហមេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ខ្លួនបានប្រើប្រាស់នូវ"នីតិវិធីដោះស្រាយតាមប្រព័ន្ធច្បាប់ជាតិ" អស់ពីលទ្ធភាពហើយ មុននឹងព្យាយាមបញ្ជូនករណីនេះទៅចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយវានឹងពុំទទួលបានដំណោះស្រាយអ្វីឡើយ ប្រសិនបើរង់ចាំការដោះស្រាយលើករណីនេះពីរាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ[៣១]។

---

[៣០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៣ និងសំណើលើកទីដប់មួយ កថាខណ្ឌ១៨-២១។

[៣១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣១-៣៣។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

00364059



៣២. ទាក់ទិនទៅនឹងបញ្ហាទាំងនេះដែលសហមេធាវីការពារក្តីបានលើកឡើង, វិធាន២១ នៃវិធានផ្ទៃក្នុង ចែងថា៖

"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមានត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ [...]"។

៣៣. អង្គបុរេជំនុំជម្រះនឹងពិនិត្យថាតើវិធាន២១នៃវិធានផ្ទៃក្នុងតម្រូវឱ្យអង្គបុរេជំនុំជម្រះ ធ្វើការបកស្រាយតាមន័យទូលាយចំពោះសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែរឬទេ ដើម្បីធ្វើយ៉ាងណាការពារផលប្រយោជន៍របស់ជនត្រូវចោទចំពោះនីយ័តភាព តម្លាភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។

៣៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងបើកឱ្យជនត្រូវចោទលើកបញ្ហាណាមួយ ដែលទាក់ទងនឹងអនិយ័តភាពនៃកិច្ចដំណើរការនីតិវិធីក្នុងការប្រើប្រាស់ភស្តុតាង តាមរយៈនីតិវិធីប្តឹងមោឃភាពក្នុងដំណាក់កាលស៊ើបអង្កេត និងនីតិវិធីជំទាស់ទៅនឹងការទទួលយកភស្តុតាងនៅក្នុងអំឡុងពេល



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ជំនុំជម្រះលើអង្គសេចក្តី យោងតាមបទប្បញ្ញត្តិនៃវិធាន៤៨ វិធាន៧៦ និងវិធាន៨៧ នៃវិធានផ្ទៃក្នុង[៣២]។

៣៥. អនុលោមតាមវិធានទាំងនេះ នៅក្នុងវិធានផ្ទៃក្នុង ភស្តុតាងដែលទទួលបានមិនត្រឹមត្រូវអាចត្រូវបានដកចេញពីសំណុំរឿង នៅពេលមានការរកឃើញថាមានកំហុសនីតិវិធីចំពោះនីតិវិធីនៃការទទួលយក ឬប្រើប្រាស់ភស្តុតាង និងនៅពេលមានការបង្ហាញថា កំហុសនីតិវិធីបែបនោះ ជាការរំលោភបំពានសិទ្ធិទាំងឡាយរបស់ភាគីនៃកិច្ចដំណើរការនីតិវិធី ដែលក្នុងនោះរួមមានជនត្រូវចោទដែរ។

៣៦. វិធាន៧៦(២)នៃវិធានផ្ទៃក្នុងចែងថា ភាគីដែលស្នើសុំមោឃភាពផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវតែដាក់ពាក្យសុំ “ដោយបញ្ជាក់មូលហេតុ”ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ វិធាន៧៦(៤)នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនេះអាចទទួលយកបាន ប្រសិនបើពាក្យសុំបង្ហាញ “ហេតុផលគ្រប់គ្រាន់ក្នុងការប្រកាសមោឃភាព”។ យោងតាមអនុវិធានទាំងនេះ អត្ថិ-ភាពនៃ “ហេតុផលគ្រប់គ្រាន់” គឺជាបុរេលក្ខខណ្ឌ ដើម្បីអាចឱ្យពាក្យសុំនោះទទួលយកបាន និងអាចឱ្យមានចំណាត់ការលើសំណើសុំមោឃភាពនោះ។ ដោយសារតែវិធានផ្ទៃក្នុងពុំបានបកស្រាយអំពីអត្ថន័យនៃ “ហេតុផលគ្រប់គ្រាន់ក្នុងការប្រកាសមោឃភាព” អង្គបុរេជំនុំជម្រះបានពន្យល់ពាក្យនេះយ៉ាងក្បោះក្បាយរួចហើយកាលពីលើកមុន ដោយខ្លួនបានសន្និដ្ឋានថា ភាគីដាក់ពាក្យសុំមោឃភាពមានកាតព្វកិច្ចត្រូវលើកឡើងថា ផ្នែកណាមួយនៃដំណើរការនីតិវិធីត្រូវប្រកាសមោឃៈ ហើយត្រូវផ្តល់មូលហេតុចំពោះការស្នើសុំមោឃភាពនោះ[៣៣]។

---

[៣២] ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់ចំពោះបទប្បញ្ញត្តិនៃវិធាន៨៧នៃវិធានផ្ទៃក្នុង សូមអានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩, E43/4 កថាខណ្ឌ ៥-៧។

[៣៣] សាលដីការបស់អ.ប.ជលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, D55/I/8 កថាខណ្ឌ៣២-៤២។

៣៧. បន្ថែមលើចំនុចនេះ នៅក្នុងដំណាក់កាលជំនុំជម្រះ ជនត្រូវចោទអាចស្នើសុំឱ្យសួរដេញដោលសាក្សីទាំងឡាយបាន ប្រសិនខ្លួនមានការព្រួយបារម្ភខ្លាំងចំពោះភស្តុតាងជាលាយលក្ខណ៍អក្សរ[៣៤]។ នៅពេលសម្រេចលើភាពអាចទទួលយកបាននៃភស្តុតាងចំពោះមុខខ្លួន អង្គជំនុំជម្រះនីមួយៗមានអំណាចជាប់មកជាមួយធ្វើការស៊ើបអង្កេតបន្ថែម ប្រសិនបើមានបញ្ហាកើតឡើងលើការជំនុំជម្រះដោយយុត្តិធម៌ លើផ្នែកណាមួយនៃភស្តុតាង។[៣៥] ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលអាចសើរើសាលក្រម ដោយផ្អែកលើមូលហេតុថា "ខ្លួនទើបរកឃើញនាពេលថ្មីៗថា ភស្តុតាងដែលយកមកពិចារណានៅក្នុងដំណាក់កាលជំនុំជម្រះ ហើយដែលយកមកធ្វើជាភស្តុតាងដាក់ទោសនោះ គឺជាភស្តុតាងមានកំហុស មានការប្រឌិតឡើង និងមានការក្លែងបន្លំ"[៣៦]។

៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សហមេធាវីការពារក្តីបានស្នើសុំឱ្យព្រះរាជអាជ្ញាអមសាលាដំបូងក្រុងភ្នំពេញស៊ើបអង្កេតលើអំពើពុករលួយដែលបានចោទប្រកាន់។ ទោះបីជាអង្គបុរេជំនុំជម្រះពុំដឹងច្បាស់ថាតើសំណើនេះផ្អែកលើមូលដ្ឋានអ្វីក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថាសហមេធាវីការពារក្តីបានផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជានៅក្នុងសំណើរបស់ខ្លួន ដើម្បីសុំឱ្យមានការបើកការស៊ើបអង្កេតលើអំពើពុករលួយទាំងនេះ។ សំណើនេះត្រូវបានសាលាដំបូងក្រុងភ្នំពេញតម្កល់ទុកឥតចាត់ការ ប៉ុន្តែ ការបដិសេធលើសំណើនេះបានបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ទៅអគ្គព្រះរាជអាជ្ញា នាពេលបច្ចុប្បន្ន។

៣៩. ជាពិសេស នៅក្នុងករណីនេះ ដោយសារសាលាដំបូងក្រុងភ្នំពេញពុំបានផ្តល់សម្អាងហេតុអំពីសេចក្តីសម្រេចរបស់ខ្លួនជូនអង្គបុរេជំនុំជម្រះ ហើយក្នុងពេលបច្ចុប្បន្ននេះ បញ្ហានេះកំពុងស្ថិតនៅចំពោះមុខសាលាឧទ្ធរណ៍នៅឡើយ យើងពុំអាចសន្និដ្ឋានថា ស្ថាប័នជាតិពុំមានសមត្ថភាព ឬពុំមានភាពអនាគតិ ដែលជាលក្ខខណ្ឌតម្រូវចាំបាច់ក្នុងការដោះស្រាយលើបញ្ហានេះឡើយ។

---

[៣៤] សូមអានវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[៣៥] សូមអានមាត្រា ៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។ *Prosecutor v. Tadic*, IT-94-1-A,"Judgment", 15 July 1999, para. 322; United States of America on Behalf of Lehigh Railroad Company v. Germany, U.S. – German Mixed Claims Commission, reprinted in 34 AM. J.I.L. 151, (1940).

[៣៦] វិធាន ១១២(១)(ខ)នៃវិធានផ្ទៃក្នុង។

៤០. អង្គបុរេជំនុំជម្រះសង្កេតឃើញទៀតថា ទោះបីជាអំពើពុករលួយនេះអាចនាំឱ្យភាពអាប់អោន ឬភាពអាម៉ាសយ៉ាងណាក៏ដោយ ដូចដែលសហមេធាវីការពារក្តីបានលើកឡើង, ភាពអាប់អោន ឬភាពអាម៉ាសនេះ ពុំមែនជាលក្ខខណ្ឌនាំឱ្យការចាត់ការលើអំពើពុករលួយនេះពុំមានប្រសិទ្ធិភាពឡើយ[៣៧]។

៤១. អង្គបុរេជំនុំជម្រះយល់ឃើញថា បទដ្ឋានដែលបានចែងនៅក្នុងថ្នាក់អន្តរជាតិដើម្បីបង្ហាញឲ្យឃើញថា ដំណោះស្រាយនៅថ្នាក់ជាតិពុំមានប្រសិទ្ធភាពនោះ មានលក្ខណៈតឹងរ៉ឹងណាស់ ។ ដោយសារតែវិធាន ឬយុត្តិសាស្ត្រទាំងឡាយរបស់តុលាការពិសេស ឬតុលាការព្រហ្មទណ្ឌអន្តរជាតិពុំបានចែងអំពីបទដ្ឋានណែនាំចំពោះបញ្ហានេះ ពីព្រោះតុលាការទាំងនេះមានយុត្តាធិការចម្បងលើយុត្តាធិការជាតិផ្សេងៗគ្នា, យើងអាចយកច្បាប់យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មកប្រើប្រាស់ជាបទដ្ឋានណែនាំ។

៤២. នៅពេលកំពុងរង់ចាំការដោះស្រាយតាមនីតិវិធីជាតិ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ អាចព្យួរនីតិវិធីនៃការទទួលយកបណ្តឹងសិន ឬក៏ប្រកាសថាបណ្តឹងនោះពុំអាចទទួលយកបានតែម្តង[៣៨]។ ចំពោះបន្ទុកនៃការបង្ហាញភស្តុតាងនៅក្នុងករណីបែបនេះ ប្រសិនបើម្ចាស់បណ្តឹងលើកឡើងថា នីតិវិធីដោះស្រាយណាមួយគ្មានប្រសិទ្ធភាព ឬពុំទទួលបានដំណោះស្រាយ ឬអាចអូសបន្លាយពេលយូរពុំសមហេតុផលនោះ ភាគីត្រូវផ្តល់ភស្តុតាងឱ្យបានច្បាស់លាស់ ដើម្បីគាំទ្រដល់ការចោទប្រកាន់របស់ខ្លួន[៣៩]។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានកត់សំគាល់ថា "ប្រសិនបើវាគ្រាន់តែជាមន្ទិលសង្ស័យចំពោះប្រសិទ្ធភាពនៃនីតិវិធីដោះស្រាយតែប៉ុណ្ណោះ ករណីនេះពុំអាចធ្វើឱ្យកាតព្វកិច្ចដោះស្រាយលើរឿងក្តីណាមួយពុំមានប្រសិទ្ធភាពឡើយ" ហើយម្ចាស់បណ្តឹងត្រូវតែដាក់ជូននូវព័ត៌មានឲ្យបានគ្រប់គ្រាន់ ឬព័ត៌មានពាក់ព័ន្ធនឹងករណីចោទ

---

[៣៧] សូមអានកថាខណ្ឌ៣១ ខាងលើ។

[៣៨] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary,* Strasbourg: 1993, p. 704.

[៣៩] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary,* Strasbourg: 1993, p. 706.

00364063



ប្រកាន់ចំពោះតុលាការដែលពុំបានអនុវត្តនីតិវិធីដោះស្រាយឱ្យមានប្រសិទ្ធភាព ដើម្បីឲ្យគណៈកម្មាធិការធ្វើការពិចារណា និងធ្វើការសេចក្ដីសន្និដ្ឋានលើបញ្ហានេះបាន[៤០]។

៤៣. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហមេធាវីការពារក្ដីជនត្រូវចោទពុំបានផ្ដល់នូវព័ត៌មានទាំងឡាយនៅក្នុងសំណើលើកទីដប់មួយ ឬក៏នៅក្នុងបណ្ដឹងឧទ្ធរណ៍ បញ្ជាក់អំពីការអះអាងរបស់ខ្លួនអំពីប្រសិទ្ធិភាព ឬក៏ការបំពេញការងាររបស់ស្ថាប័នក្នុងស្រុក ដែលកំពុងពិនិត្យសំណើរបស់ខ្លួនឬសំណើរបស់អង្គការសហប្រជាជាតិ។

៤៤. អង្គបុរេជំនុំជម្រះយល់ឃើញថា អនុលោមតាមវិធានផ្ទៃក្នុង និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា សហមេធាវីការពារក្ដីមានលទ្ធភាពដាក់បណ្ដឹង និងសុំឱ្យដោះស្រាយតាមនីតិវិធីផ្សេងទៀត ដែលការពារយ៉ាងគ្រប់គ្រាន់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ។

៤៥. ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា លិខិតុបករណ៍បង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង និងលិខិតុបករណ៍អន្តរជាតិនានា បានធានាដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនម្អៀង ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋហត្ថលេខី។

៤៦. មាត្រា ១២ នៃកិច្ចព្រមព្រៀងចែងដូចខាងក្រោមនេះ ៖

> "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ [....]"

---

[៤០] *Garcia Perea v. Spain*, Communication No. 1511/2006, "Decision of the Human Rights Committee", 27 March 2009, para. 6.2.



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៤៧. មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវឱ្យរដ្ឋជាភាគីទាំងអស់បង្កើតតុលាការដែលមានឯករាជ្យ និងមិនលម្អៀង ហើយផ្តល់ឱ្យតុលាការទាំងនោះនូវរចនាសម្ព័ន្ធនៃស្ថាប័នមួយ និងហិរញ្ញវត្ថុមួយ ដែលអាចឱ្យតុលាការទាំងនោះអនុវត្តការជំនុំជម្រះក្តីរឿងព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌គ្រប់ពេលវេលា និងផ្តល់ឱ្យគ្រប់ជនជាប់ចោទទាំងអស់នូវសិទ្ធិជាអប្បបរិមាដែលមានធានានៅក្នុងមាត្រា ១៤(២)-(៧)[៦១]។

៤៨. ចំពោះអនាគតនៃចៅក្រមរបស់ អ.វ.ត.ក, អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ៣៤ នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិឱ្យភាគីនានាលើកឡើងអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាផលប្រយោជន៍ជាក់លាក់ ឬភាពលម្អៀងរបស់ចៅក្រម ទៅតាមករណីនីមួយៗ។

៤៩. ពាក់ព័ន្ធនឹងឯករាជ្យភាពរបស់ចៅក្រមរបស់ អ.វ.ត.ក, មាត្រា ៣ នៃកិច្ចព្រមព្រៀង និងមាត្រា ១១ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងយោងលើបញ្ហានេះ។ កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាស្ថាប័នជ្រើសតាំង និងតែងតាំងចៅក្រមសម្រាប់ អ.វ.ត.ក។ សហមេធាវីការពារក្តីជនត្រូវចោទបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានទាំងឡាយថា អត្ថិភាពនៃ“ប្រព័ន្ធបង់ប្រាក់សំណូក” អាចធ្វើឱ្យប៉ះពាល់ដល់របៀបនៃការតែងតាំងចៅក្រមសម្រាប់ អ.វ.ត.ក ហេតុដូច្នេះហើយបង្កើតជាបញ្ហាចោទលើឯករាជ្យភាពរបស់ចៅក្រមពីស្ថាប័នរដ្ឋបាល។ សហមេធាវីការពារក្តីជនត្រូវចោទលើកទឡ្ហីករណ៍បន្ថែមទៀតថា ប្រសិនបើបុគ្គលិកដែលទទួលភារកិច្ចបំពេញការងាររសើប មានឆន្ទៈចូលរួមពាក់ព័ន្ធនៅក្នុងអំពើពុករលួយនោះ នៅពេលនោះបុគ្គលទាំងនោះក៏អាចនឹងមានឆន្ទៈដូចគ្នាក្នុងការអនុវត្តតាមសេចក្តីណែនាំដែលមិនសមស្របផងដែរ ហើយវាធ្វើឱ្យប៉ះពាល់ដល់សេចក្តីសុចរិតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។

---

[៦១] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary*, Strasbourg: 1993, p. 238.



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៥០. អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់អំពីមន្ត្រីបុគ្គលិកប្រហែលជាបានបង់ប្រាក់ទៅឱ្យថ្នាក់លើនោះ មិនអាចនាំឱ្យមានការសន្និដ្ឋានថា មន្ត្រីបុគ្គលិកទាំងនេះអាចមានឥទ្ធិពលបញ្ចុះបញ្ចូលចៅក្រម ឱ្យរៀបចំលទ្ធផលនៃកិច្ចនីតិវិធី ហើយធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាព និង អនាគតិរបស់តុលាការ ឬក៏ចៅក្រមបានឡើយ។ លក្ខណៈនៃការចោទប្រកាន់បែបនេះ គឺទូលំទូលាយពេកមិនអាចឱ្យធ្វើការសន្និដ្ឋានបែបនេះឡើយ លើកលែងតែមានផ្តល់អង្គហេតុបន្ថែមផ្សេងទៀត។

៥១. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនត្រូវចោទដូចមានចែងនៅក្នុងវិធាន ២១នៃវិធានផ្ទៃក្នុង ត្រូវបានការពារយ៉ាងពេញលេញដោយក្របខ័ណ្ឌច្បាប់ជាធរមាន ដូចដែលបានផ្តល់សម្អាងហេតុខាងលើ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១នៃវិធានផ្ទៃ មិនបានចាប់បង្ខំឱ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយក្នុងន័យឱ្យខ្លួនប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះបានឡើយ។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ÷**

បណ្តឹងឧទ្ធរណ៍នេះ គឺមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING — ន័យ ធុល — Katinka LAHUIS — ហួត វុទ្ធី — [signature]

**ក្រឡាបញ្ជី**

សរ ច័ន្ទវិត — Eutela JOSIFI